# សេចក្តីប្រកាសព័ត៌មាន

## ពិធីផ្សព្វផ្សាយឯកសាររបស់អង្គភាពច្បាប់

ស្តីពី

*សៀវភៅស្តីពីការជំនុំជម្រះក្តីដោយយុត្តិធម៌*

*របាយការណ៍ប្រចាំឆ្នាំស្តីពីការឃ្លាំមើលតុលាការ ឆ្នាំ ២០០៦*

*ព្រឹត្តិបត្រអ្នកឃ្លាំមើលតុលាការ លេខ ១៦*

---

ភ្នំពេញ ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០០៧ ៖ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (ម.អ.ស.) ជាអង្គការមិនមែនរដ្ឋាភិបាល មានសេចក្តីសោមនស្សរីករាយ នឹងប្រកាសការចេញផ្សាយឯកសារចំនួនបីប្រភេទ ស្តីពីការឃ្លាំមើលតុលាការ ៖

- **សៀវភៅស្តីពីការជំនុំជម្រះក្តីដោយយុត្តិធម៌**
- **របាយការណ៍ប្រចាំឆ្នាំស្តីពីការឃ្លាំមើលតុលាការ ឆ្នាំ ២០០៦**
- **ព្រឹត្តិបត្រអ្នកឃ្លាំមើលតុលាការ លេខ ១៦**

**កម្មវិធីសង្កេតការណ៍តុលាការ** នៃមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម បានឃ្លាំមើលតុលាការនៅកម្ពុជាយ៉ាងសកម្ម ចាប់តាំងពីបំណាច់ឆ្នាំ ២០០៣ និង បានទទួលមូលនិធិពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (ដំបូងតាមរយៈអង្គការមូលនិធិអាស៊ី និង បច្ចុប្បន្ន តាមរយៈ វិទ្យាស្ថានគ្រប់គ្រងបូព៌ា-បច្ចឹម) ។ ជារៀងរាល់ឆ្នាំ ម.អ.ស. ផ្សព្វផ្សាយ *ព្រឹត្តិបត្រអ្នកឃ្លាំមើលតុលាការ* ចំនួនបួន និង របាយការណ៍ប្រចាំឆ្នាំមួយ ។ របាយការណ៍ទាំងនេះត្រូវបានតាក់តែងចងក្រង ដោយមន្ត្រីផ្នែកច្បាប់នៃ ម.អ.ស. ដែលឃ្លាំមើលសវនាការនៅតុលាការជារៀងរាល់ថ្ងៃ ។

នៅក្នុងឆ្នាំ ២០០៦ ម.អ.ស. បានកត់សំគាល់នូវការប្រសើរឡើងខ្លះ ក៏ដូចជាបញ្ហាមួយចំនួន ដែលនៅតែកើតមាននៅក្នុងប្រព័ន្ធតុលាការកម្ពុជា ។ ជាពិសេសនោះ ការបំពាន “**សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌**” សំខាន់ៗជាច្រើននៅតែបន្តកើតមាន ។

ជារឿយៗ សច្ចាធារណ៍នៃនីរទោស ឬ ការសន្មតជាមុនថាគ្មានទោស ដែលជាការការពារយ៉ាងសំខាន់ របស់បុគ្គលម្នាក់ៗទល់នឹងយន្តការរបស់រដ្ឋ តែងត្រូវបានបំពានយ៉ាងច្បាស់នៅក្នុងរឿងក្តីខ្លះ និង ដោយស្ងាត់ស្ងៀមនៅក្នុងរឿងក្តីខ្លះទៀត ។ ចៅក្រមជាច្រើន ប្រព្រឹត្តមកលើជនជាប់ចោទដូចជាអ្នកមានកំហុស នៅមុនពេលដែលការជំនុំជម្រះក្តីចេញជាលទ្ធផល ដោយប្រើសំនួរដឹកមុខ និង សំនួរដែលបង្ហាញពីកំហុស ព្រមទាំងច្រើនតែរំពឹងថាមេធាវីការពារ

ជនជាប់ចោទ នឹងលើកយកភស្តុតាងមកបង្ហាញថាការចោទប្រកាន់របស់អយ្យការមិនត្រឹមត្រូវ ។ នៅពេលមានការលើកឡើងពីការធ្វើទារុណកម្មដើម្បីយកចម្លើយសារភាព ចៅក្រមជាច្រើន បានត្រឹមតែព្រងើយកន្តើយនឹងការលើកឡើងនេះព្រមទាំងបន្តសវនាការ ដោយមិនធ្វើការស៊ើបសួរបន្ថែមលើចំនុចនេះ ។

ការធ្វើទារុណកម្មដើម្បីយកចម្លើយសារភាព ដោយមន្ត្រីនគរបាលយុត្តិធម៌ បានលើកឡើងដោយជនជាប់ចោទជាច្រើន ។ បញ្ហានេះ ក៏ត្រូវបានទទួលស្គាល់ផងដែរដោយសម្តេចនាយករដ្ឋមន្ត្រី ។ ប៉ុន្តែ ចៅក្រមកម្របញ្ជាឲមានការស៊ើបអង្កេតទៅលើការអះអាងពីការធ្វើទារុណកម្មនេះណាស់ ។

សិទ្ធិមានទីប្រឹក្សាច្បាប់ ដែលជាមធ្យោបាយចំបងបំផុត សំរាប់ឲជនជាប់ចោទក្នុងរឿងព្រហ្មទណ្ឌ ការពារសិទ្ធិផ្សេងទៀតរបស់ខ្លួន មិនត្រូវបានគោរព ។ នៅក្នុងរឿងក្តីជាច្រើនដែល ម.អ.ស. បានឃ្លាំមើល ទីប្រឹក្សាច្បាប់មិនមានវត្តមាននៅពេលសវនាការ ឬ គ្រាន់តែទទួលការពាររឿងក្តី ដោយមិនមានពេលគ្រប់គ្រាន់ដើម្បីរៀបចំការការពារ ឬ សូម្បីតែប្រាស្រ័យទាក់ទងជាមួយកូនក្តីរបស់ខ្លួន ។ កង្វះខាតមេធាវីប្រកបវិជ្ជាជីវៈ ក៏ជាមូលហេតុនៃការបំពាននេះមួយផ្នែកផងដែរ ។ ភាពគ្មានប្រសិទ្ធភាពនៃការការពារ ក៏ត្រូវបានកត់សំគាល់ផងដែរដោយ ម.អ.ស. នៅឆ្នាំមុននេះ ។ ក្នុងចំនោមរឿងក្តីជាច្រើនដែលបានសង្កេតមើល ជនរងគ្រោះ និង សាក្សីជាច្រើន មិនមានវត្តមាននៅពេលជំនុំជម្រះក្តី ។ ហេតុដូច្នេះសិទ្ធិរបស់ជនជាប់ចោទក្នុងការសាកសួរ និង សួរដេញដោលសាក្សីដោយផ្ទាល់ ក៏មិនត្រូវបានគោរពផងដែរ ។

បញ្ហាជុំវិញសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះដោយមិនពន្យារពេល ក៏ត្រូវបានកត់សំគាល់ផងដែរជាពិសេស នៅពេលដែលជនជាប់ចោទស្ថិតក្នុងឃុំ ។ តុលាការបញ្ជាឲឃុំខ្លួនបណ្តោះអាសន្ន និង ពន្យារពេលការឃុំខ្លួននេះ លើសពីរយៈពេលកំណត់ដោយច្បាប់ ។ នៅក្នុងរឿងក្តីខ្លះ ម.អ.ស. បានសង្កេតឃើញមានជនជាប់ចោទស្ថិតនៅក្នុងឃុំលើសមួយឆ្នាំ ។ ក្នុងនោះ ជនជាប់ចោទខ្លះមានអាយុតិចជាង ១៨ ឆ្នាំ ។ ក្រៅពីការសំរេចឲឃុំខ្លួនបណ្តោះអាសន្នច្រើនហួសហេតុពេក ក៏ដូចជាការអូសបន្លាយពេលវេលាលើសពីកាលកំណត់ដោយច្បាប់ ម.អ.ស. ក៏បានប្រទះឃើញមានការប្រើនូវទោសពន្ធនាគារ ច្រើនហួសហេតុផងដែរ ដែលនេះ ផ្ទុយនឹងទស្សនៈដើមនៃទោស ។

នៅពេលឃ្លាំមើលតុលាការ អ្នកសង្កេតការណ៍តុលាការរបស់ ម.អ.ស. ក៏មានការចាប់អារម្មណ៍ផងដែរ ទៅលើការបំពានសិទ្ធិរបស់ជនជាប់ចោទជាអនីតិជន ។ ថ្វីបើជនជាប់ចោទជាអនីតិជន ត្រូវការការប្រព្រឹត្តជាពិសេសមកលើខ្លួនដោយអាជ្ញាធរពាក់ព័ន្ធក្តី ក៏ចៅក្រមខ្លះនៅតែប្រព្រឹត្តមកលើជនជាប់ចោទអនីតិជនទាំងនោះ ដូចជាពេលប្រព្រឹត្តទៅលើជនជាប់ចោទជានីតិជនដែរ ឬ ផ្តន្ទាទោសពួកគេដល់កំរិតអតិបរិមានៃទោសដែលច្បាប់អនុញ្ញាត ។

សរុបមក ការគោរពសិទ្ធិនានារបស់ជនជាប់ចោទដោយតុលាការមិនបានប្រសើរឡើងទេ បើប្រៀបធៀបនឹងឆ្នាំ ២០០៥ ។

បញ្ហានានាដែលលើកឡើងនៅក្នុងរបាយការណ៍ឆ្នាំ ២០០៦ នេះ ទាមទារនូវសកម្មភាពជាក់លាក់ផ្សេងៗ ដើម្បីដោះស្រាយបញ្ហាជាក់លាក់ទាំងនេះ ។ ម.អ.ស. ជឿជាក់ថា ដំណោះស្រាយមួយសំរាប់បញ្ហាជាច្រើន គឺស្ថិតនៅលើការហ្វឹកហ្វឺនដ៏ប្រសើរសំរាប់មេធាវី ព្រះរាជអាជ្ញា និង ចៅក្រម មិនមែនសំរាប់តែមនុស្សជំនាន់ថ្មី ដែលកំពុងតែសិក្សានៅមជ្ឈមណ្ឌល

បណ្តុះបណ្តាល និង សុក្រឹតការវិជ្ជាជីវៈមេធាវី ឬ នៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការប៉ុណ្ណោះទេ ប៉ុន្តែតាមរយៈការអប់រំច្បាប់បន្តសំរាប់បុគ្គលិកតុលាការ និង អ្នកជំនាញច្បាប់ដែលមានស្រាប់ ។ ការណ៍នេះ នឹងលើកកំពស់នូវការយល់ដឹងឲកាន់តែប្រសើរឡើងនៃ "សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌" ក៏ដូចជាការយល់ដឹងពីសារៈសំខាន់ និង ការអនុវត្តសិទ្ធិនេះផងដែរ ។

សៀវភៅស្តីពីការជំនុំជម្រះក្តីដោយយុត្តិធម៌ ត្រូវបានតាក់តែងឡើងជាពិសេស ដើម្បីជួយណែនាំមន្ត្រីតុលាការដែលពាក់ព័ន្ធនៅក្នុងការអនុវត្តកាតព្វកិច្ចជាអ្នកការពារនីតិរដ្ឋ និង ការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ សៀវភៅនេះលំអិតនូវធាតុផ្សំនីមួយៗនៃសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដោយមានអមមកជាមួយនូវរូបភាពផ្សេងៗ ។ សៀវភៅនេះក៏ពន្យល់ផងដែរនូវសារៈសំខាន់នៃការឃ្លាំមើលសិទ្ធិទាំងនេះ ដែលជាសសរគោលនៃការពង្រឹងនីតិរដ្ឋនៅកម្ពុជា ។

---

### អំពីមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម

មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ("ម.អ.ស.") គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញ និង ជាអង្គការមិនមែនរដ្ឋាភិបាល ។ ម.អ.ស. ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៥ (ទទួលស្គាល់ដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ ១៩៩៥ និង ដោយក្រសួងមហាផ្ទៃ នៅឆ្នាំ ២០០១) និង ស្វែងរកលើកតម្កើនតម្លៃនៃលទ្ធិប្រជាធិបតេយ្យ ព្រមទាំងធ្វើឲប្រសើរឡើងនូវគុណភាពនៃជីវិតរបស់ជនកម្ពុជា ។

បេសកកម្មរបស់ ម.អ.ស. គឺជំរុញលើកទឹកចិត្តឲមានការចូលរួមយ៉ាងទូលំទូលាយ (ទាំងថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាន) នៅក្នុងកិច្ចការសាធារណៈ បង្កើនការគោរពសិទ្ធិមនុស្ស និង នីតិរដ្ឋ លើកកំពស់តម្លាភាព និង ការអនុវត្តភាពទទួលខុសត្រូវជាសាធារណៈគ្រប់លំដាប់ថ្នាក់ និង លើកឡើងពីការយល់ដឹងអំពីបញ្ហានានាជុំវិញកង្វល់ជាតិក្រោមទម្រង់ផ្សេងៗនៃសារព័ត៌មាន ។ ម.អ.ស. មានអង្គភាពប្រតិបត្តិសំខាន់ៗប្រាំ និង គម្រោងថ្មីពីរទៀត ដើម្បីបំពេញបេសកកម្មនេះ ៖ (i) អង្គភាពច្បាប់ (ii) អង្គភាពអភិបាលកិច្ច (iii) អង្គភាពវេទិកាសាធារណៈ (iv) អង្គភាពបោះឆ្នោត និង សភា (v) អង្គភាពស្រាវជ្រាវ និង បោះពុម្ពផ្សាយ (vi) កម្មវិធីសាកល្បងនៅក្រុងកែប i-REACH និង (vii) កម្មវិធី*សំលេងយុត្តិធម៌* ។